ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០៧.....សហវ.[illegible]

ក្រសួងមហាផ្ទៃ

# សារាចរអន្តរក្រសួង
## ស្តីពី
## ការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់

រាជរដ្ឋាភិបាលផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ តាមរយៈអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ ដោយបែងចែកជា ៣ សមាសភាគ គឺ (១) សមាសភាគរដ្ឋបាលទូទៅ (២) សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន និង (៣) សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។ ផ្អែកលើមូលដ្ឋាននេះ ដើម្បីពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម សម្រាប់ការគ្រប់គ្រង និងការចាត់ចែងអនុវត្តសមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ អំពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ដូចតទៅ៖

### ១. អំពីគម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន

រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវប្រើធនធានថវិកាសេវាសង្គម និងអនាម័យបរិស្ថាន ក្នុងគោលដៅលើកកម្ពស់និងគាំទ្រសេវាសង្គម អនាម័យបរិស្ថាន គោលនយោបាយភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព និងគណនេយ្យភាពសង្គម ព្រមទាំងវិធានការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។

គម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានរបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ រួមមាន៖ (១)ការលើកកម្ពស់សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ, (២)ពង្រឹងនិងពង្រីកការអប់រំកុមារតូច, (៣)ការលើកកម្ពស់គុណភាពអប់រំបឋមសិក្សា និងមធ្យមសិក្សា, (៤) កិច្ចការពារស្ត្រី និងកុមារ, (៥)ការលើកកម្ពស់សមភាពយេនឌ័រ, (៦)កិច្ចអន្តរាគមន៍គាំទ្រ និងជំរុញការអនុវត្តកិច្ចគាំពារសង្គម, (៧)ពង្រឹងការយល់ដឹង និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លង និងជំងឺមិនឆ្លង, (៨)ការលើកកម្ពស់គណនេយ្យភាពសង្គម, (៩)ទឹកស្អាត និងអនាម័យ, (១០)ការគ្រប់គ្រងសំណល់រឹង រាវ, និង(១១)ការប្រែប្រួលអាកាសធាតុ។

មុខសញ្ញាចំណាយ គម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន អាចធ្វើបច្ចុប្បន្នភាពតាមការចាំបាច់ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃសង្គមសេដ្ឋកិច្ច និងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

ផ្អែកតាមតារាងវិភាជន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំមុខសញ្ញាអាទិភាពប្រចាំឆ្នាំទៅតាមស្ថានភាពមូលដ្ឋានជាក់ស្តែងដោយជ្រើសរើសចេញពីមុខសញ្ញាក្នុងតារាងឧបសម្ព័ន្ធ។

## ២. ការរៀបចំ ការអនុម័ត និងការអនុវត្ត

រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ត្រូវធានាថា គម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ត្រូវបានចាត់អាទិភាព និងដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលសាមី។ ផ្អែកតាមកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលសាមី រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំសម្របសម្រួលអង្គភាព និងអ្នកពាក់ព័ន្ធក្នុងការរៀបចំថវិកាសេវាសង្គម និងអនាម័យបរិស្ថានប្រចាំឆ្នាំទៅតាមទំហំកំណត់ ដែលបានវិភាជដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ព្រមទាំងថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងប្រភពស្របច្បាប់ផ្សេងទៀត ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- រដ្ឋបាលក្រុង ស្រុក ដែលមានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងការិយាល័យជំនាញពាក់ព័ន្ធក្រោមឱវាទជាសេនាធិការ ត្រូវរៀបចំគម្រោងថវិកាប្រចាំឆ្នាំដែលពាក់ព័ន្ធនឹងគម្រោង ឬសកម្មភាពនៃចំណុចទី១ខាងលើនេះ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ហើយត្រូវអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ស្របតាមនីតិវិធីជាធរមាន។
- រដ្ឋបាលឃុំ សង្កាត់ ដែលមានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងអ្នកពាក់ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ជាសេនាធិការ ត្រូវរៀបចំគម្រោងថវិកាប្រចាំឆ្នាំដែលពាក់ព័ន្ធនឹងគម្រោង ឬសកម្មភាពនៃចំណុចទី១ខាងលើនេះ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ហើយត្រូវអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាមនីតិវិធីជាធរមាន។

ដើម្បីធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព នៃការប្រើធនធានថវិកាសេវាសង្គម និងអនាម័យបរិស្ថាន រដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យភាពប្រទាក់ក្រឡាគ្នា បំពេញគ្នាលើការគ្រោងថវិកានេះ មុននឹងដាក់ជូនអភិបាលរាជធានី ខេត្ត ពិនិត្យនិងផ្តល់អនុលោមភាពលើគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។

រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវជ្រើសរើសមាតិកាថវិកាចំណាយទៅតាមមុខសញ្ញាគម្រោង ឬសកម្មភាព ដើម្បីទូទាត់ចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន ដែលមានក្នុងឧបសម្ព័ន្ធ និងអនុវត្តតាមនីតិវិធីចំណាយធម្មតា ឬទូទាត់ត្រង់ និងនីតិវិធីបើកផ្តល់សាច់ប្រាក់មុន ឬចំណាយតាមរជ្ជទេយ្យបុរេប្រទាន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៣. របាយការណ៍ និងការគាំទ្រ

រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំរបាយការណ៍ចំណូល ចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន និងរបាយការណ៍លទ្ធផលនៃការអនុវត្តគម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ពិនិត្យ និងអនុម័ត។ របាយការណ៍នេះ ជាផ្នែកមួយនៃរបាយការណ៍ចំណូល ចំណាយថវិកា និងរបាយការណ៍អនុវត្តការងារ

ប្រចាំឆមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក។ របាយការណ៍ចំណូល ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចម្លងជូនក្រសួងមហាផ្ទៃ។ របាយការណ៍អនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ត្រូវបញ្ជូនមកក្រសួងមហាផ្ទៃ និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍ចំណូល ចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន និងរបាយការណ៍លទ្ធផលនៃការអនុវត្តគម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត។ របាយការណ៍នេះជាផ្នែកមួយនៃរបាយការណ៍ចំណូល ចំណាយថវិកា និងរបាយការណ៍អនុវត្តការងារប្រចាំឆមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់។ របាយការណ៍ចំណូល ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចម្លងជូនក្រសួងមហាផ្ទៃ។ របាយការណ៍អនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនមកក្រសួងមហាផ្ទៃ និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវសហការរៀបចំផ្សព្វផ្សាយ និងកសាងសមត្ថភាពដល់អ្នកពាក់ព័ន្ធក្នុងការរៀបចំ និងអនុវត្តថវិកាសកម្មភាព ឬគម្រោងសេវាសង្គម និងអនាម័យបរិស្ថានសម្រាប់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាននៅរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមកក្រសួង ស្ថាប័នរៀងៗខ្លួនវិញ។

ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៥

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** |
| **អភិសន្តិបណ្ឌិត ស សុខា** | **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** |

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃសារាចរអន្តរក្រសួងលេខ០០[illegible]ចុះថ្ងៃទី២៥.....ខែ.[illegible].. ឆ្នាំ២០២៥**

# ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់

| បរិយាយគម្រោង ឬសកម្មភាព / អនុគម្រោងឬអនុសកម្មភាព សេវាសង្គម និងអនាម័យបរិស្ថាន | មាតិកាថវិកា |
|---|---|
| I. **សេវាសង្គម** | |
| **១.ការលើកកម្ពស់សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ ៖** សំដៅលើការលើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភមាតា ទារក កុមារ សេវាសុខភាពមូលដ្ឋានដល់មាតា ទារក និងកុមារ ដែលមានដូចជាការចុះត្រួតពិនិត្យស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោម៥ឆ្នាំ ដើម្បីកំណត់រកអ្នកមានបញ្ហាអាហារូបត្ថម្ភ។ ការលើកកម្ពស់ការយល់ដឹងពីសុខុមាលភាពមាតា និងទារកតាមសហគមន៍ ដោយមានការរៀបចំបណ្តុះបណ្តាល កិច្ចប្រជុំ ផ្សព្វផ្សាយតាមភូមិ មណ្ឌលសុខភាព សាលាឃុំ សង្កាត់ ឬនៅតាមសាលារៀន។ | |
| ១.១.ចំណាយសម្រាប់សោហ៊ុយធ្វើដំណើរ របស់បុគ្គលិកមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ការិយាល័យស្រុកប្រតិបត្តិ និងមន្ត្រី ឬបុគ្គលិកក្រៅក្របខណ្ឌ ក្នុងការចុះត្រួតពិនិត្យស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម៥ឆ្នាំ ដើម្បីកំណត់រកអ្នកមានបញ្ហាអាហារូបត្ថម្ភ។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ១.២.ចំណាយសម្រាប់សោហ៊ុយធ្វើដំណើរ របស់បុគ្គលិកមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ការិយាល័យស្រុកប្រតិបត្តិ និងមន្ត្រី ឬបុគ្គលិកក្រៅក្របខណ្ឌ ដើម្បីផ្សព្វផ្សាយបង្កើនការយល់ដឹង និងការព្យាបាលដល់ម្តាយ និងកុមារ ដែលមានបញ្ហាអាហារូបត្ថម្ភនៅតាមសហគមន៍។ | |
| ១.៣.ចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ បង្កើនការយល់ដឹងតាមសហគមន៍ (តាមភូមិ ឬមណ្ឌលសុខភាព ឬនៅសាលាឃុំ សង្កាត់ ឬនៅតាមសាលារៀន) អំពីបញ្ហាសុខភាព និងអាហារូបត្ថម្ភរបស់មាតា និងកុមារ ក្នុងគោលដៅអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស "<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |

| | |
|---|---|
| ១.៤.ចំណាយឧបត្ថម្ភ សម្រាប់មធ្យោបាយដឹកជញ្ជូនអ្នកជំងឺ (ស្ត្រីមានផ្ទៃពោះ និងទារកទើបនឹងកើត និងកុមារដែលមានបញ្ហាអាហារូបត្ថម្ភ និងកុមារពិការ) មកពីគ្រួសារក្រីក្រ ដើម្បីទទួលបានការព្យាបាល ការពិនិត្យផ្ទៃពោះមុន និងការទទួលបានការថែទាំក្រោយសម្រាលនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យ។ | - 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ១.៥. ការចំណាយសម្រាប់សាងសង់មណ្ឌលសុខភាពថ្មី / ជួសជុលមណ្ឌលសុខភាពមានស្រាប់ សម្ភារៈសម្រាប់ការងារថែទាំ ចំណាយលើការទិញសង្ហារិម និងសម្ភារៈផ្សេងៗ ដូចជាតុ កៅអី...។ល។ សម្រាប់ដំណើរការមណ្ឌលសុខភាព និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។ | - 21031 "សំណង់អគារ"<br>- 21032 "កែលម្អអគារ"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ "<br>- 60053 "សម្ភារៈប្រើប្រាស់"<br>- 60058 "សម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខាផ្សេងៗ" |
| ១.៦. ចំណាយប្រាក់ឧបត្ថម្ភ និងសោហ៊ុយពាក់ព័ន្ធ សម្រាប់អ្នកទ្រទ្រង់សុខភាពភូមិ និងមន្ត្រីឬបុគ្គលិកក្រៅក្របខណ្ឌ អនុវត្តយុទ្ធនាការផ្សព្វផ្សាយ បង្កើនការយល់ដឹងតាមសហគមន៍ (តាមភូមិ ឬមណ្ឌលសុខភាព ឬនៅសាលាឃុំ សង្កាត់ ឬនៅតាមសាលារៀន) អំពីបញ្ហាសុខភាព និងអាហារូបត្ថម្ភរបស់មាតា និងកុមារ។ | - 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61093 "បុគ្គលិកសម្ទុហភាពសាធារណៈផ្សេងៗ"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| **២.ពង្រឹងនិងពង្រីកការអប់រំកុមារតូច ៖** សំដៅដល់សកម្មភាពក្នុងការចូលរួមចំណែក លើកកម្ពស់ការអប់រំកុមារតូច នៅតាមមត្តេយ្យសហគមន៍ និងមត្តេយ្យបរិយាបន្ន (ជនជាតិភាគតិច កុមារពិការ ក្រីក្រ...)។ ការគាំទ្រដល់ការរៀបចំផែនការ ជំរុញការថែទាំ និងការអភិវឌ្ឍន៍កុមារតូច រួមទាំងការប្រមូលព័ត៌មាន និងការលើកម្ពស់ ឥរិយាបថវិជ្ជមានរបស់ឪពុកម្តាយ ក្នុងការចិញ្ចឹមបីបាច់កុមារតូច (០-ក្រោម៦ឆ្នាំ) និងកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយសហគមន៍ លើការអភិវឌ្ឍកុមារតូច។ | |
| ២.១.ចំណាយសម្រាប់សាងសង់សាលាមត្តេយ្យសហគមន៍ថ្មី សាលាមត្តេយ្យរដ្ឋថ្មី និងបង្គន់អនាម័យ សម្ភារៈផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងសម្ភារៈផ្សេងៗបំពាក់ជាមួយអគារ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។ | - 21031 "សំណង់អគារ"<br>- 21048 "ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ" |

| | |
|---|---|
| ២.២.ចំណាយលើការរៀបចំ ថែទាំ ជួសជុល សាលាមត្តេយ្យសហគមន៍/មត្តេយ្យរដ្ឋ និងសួនកុមារ រួមទាំងរបង បង្គន់អនាម័យ សម្ភារៈផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។ | - 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ"<br>- 60052 "សង្ហារិម"<br>- 60053 "សម្ភារៈប្រើប្រាស់"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ" |
| ២.៣.ចំណាយប្រាក់ឧបត្ថម្ភ សម្រាប់គ្រូដែលជួលឱ្យបង្រៀន នៅតាមសាលាមត្តេយ្យសហគមន៍ ស្របតាមប្រកាសលេខ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨។ | - 61093 "បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ" |
| ២.៤.ចំណាយសម្រាប់បំប៉ន និងបណ្តុះបណ្តាលបច្ចេកទេសរៀន និងបង្រៀន គ្រូមត្តេយ្យសហគមន៍ មិនជាប់ស្តង់ដារបស់ក្រសួងអប់រំយុវជន និងកីឡា ក្នុងគោលដៅអភិវឌ្ឍន៍សមត្ថភាពដល់អ្នកពាក់ព័ន្ធ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស" |
| ២.៥ យុទ្ធនាការផ្សព្វផ្សាយ និងជំរុញការចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សា។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ២.៦ ចំណាយសម្ភារៈសិក្សា និងអាហារសម្រន់សម្រាប់កុមារតូច។ | - 60028 "សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ"<br>- 60058 "សម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខាផ្សេងៗ"<br>- 62023 "អាហារនិងសម្ភារៈ (ស្បៀង)" |
| ២.៧ ចំណាយសោហ៊ុយធ្វើដំណើរ សម្រាប់គ្រូមត្តេយ្យសិក្សាសហគមន៍ ចុះបើកវគ្គដល់មាតាបិតា និងអ្នកថែទាំកុមារស្តីពីការចិញ្ចឹមបីបាច់កុមារតូច និងសម្រាប់ចូលរួមកិច្ចប្រជុំបច្ចេកទេស និងវគ្គបណ្តុះបណ្តាល។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |

| | |
|---|---|
| ២.៨ ចំណាយសម្រាប់បើកវគ្គដល់មាតាបិតា អាណាព្យាបាល និងអ្នកថែទាំកុមារ ស្តីពីការចិញ្ចឹមបីបាច់កុមារតូច។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស "<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| **៣.ការលើកកម្ពស់គុណភាពអប់រំបឋមសិក្សា និងមធ្យមសិក្សា ៖** គឺជាសកម្មភាពក្នុងការចូលរួមចំណែកលើកកម្ពស់សេវាអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ក្នុងនោះមានការគាំទ្រយុទ្ធនាការចុះឈ្មោះចូលរៀនរបស់សិស្ស ការលើកទឹកចិត្តដល់សិស្សមកពីគ្រួសារក្រីក្រឱ្យបន្តរៀនរហូតដល់ចប់ថ្នាក់ទី១២ និងសកម្មភាពឬវិធានការក្នុងការបង្ការការបោះបង់ការសិក្សា (កំណត់អត្តសញ្ញាណសិស្សដែលងាយបោះបង់ការសិក្សា និងការតាមដាន ការពង្រឹងសមត្ថភាពគ្រូបង្រៀន នាយកសាលានិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាលារៀន កន្លែងលេងកីឡា សួន បណ្ណាល័យ តាមការចាំបាច់របស់មូលដ្ឋាន)។ | |
| ៣.១.ចំណាយសាងសង់សាលារៀនថ្មីៗ នៅតំបន់ដាច់ស្រយាល ជួសជុលសាលារៀន រួមទាំងបង្គន់អនាម័យ សម្ភារៈផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងហេដ្ឋរចនាសម្ព័ន្ធគាំទ្រ។ | - 21031 "សំណង់អគារ "<br>- 21048 "ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ " |
| ៣.២.ចំណាយលើការរៀបចំ ថែទាំ និងជួសជុលសួនកុមារ និងកន្លែងលេងកីឡា រួមទាំង របង អគារ បង្គន់អនាម័យ និងសម្ភារៈផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅសាលាបឋមសិក្សា មធ្យមសិក្សា ព្រមទាំងចំណាយលើការទិញសង្ហារិម និងសម្ភារៈផ្សេងៗដូចជា តុ កៅអី តង់កៅស៊ូ...។ល។ | - 60053 "សម្ភារៈប្រើប្រាស់"<br>- 60052 "សង្ហារិម"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទនិងសំណង់ផ្សេងៗ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ"<br>- 61051 "ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ"<br>- 21048 "ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ" |
| ៣.៣.ចំណាយសម្រាប់ផ្តល់អាហារូបករណ៍ ដល់សិស្ស និងសិស្ស ប្រឈមនឹងការបោះបង់ការសិក្សា មកពីគ្រួសារក្រីក្រ និងងាយរងហានិភ័យ ដើម្បីឱ្យបន្តរៀនរហូតដល់បញ្ចប់ថ្នាក់ទី១២។ | - 62025 "អាហារូបករណ៍ សម្រាប់ការសិក្សាស្រាវជ្រាវ ក្នុងប្រទេស"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |

| | |
|---|---|
| ៣.៤. ចំណាយលើកម្មវិធីផ្តល់ស្បៀងអាហារដល់កុមារនៅតាមសាលារៀន។ | - 62023 "អាហារនិងសម្ភារៈ (ស្បៀង)" |
| ៣.៥. ចំណាយលើការឧបត្ថម្ភសម្ភារៈសិក្សា ដូចជាក្រដាស់ សីមី សៀវភៅ ខ្មៅដៃ ប៊ិកជាដើម។ | - 60058 "សម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខាផ្សេងៗ"<br>- 60028 "សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ" |
| ៣.៦.ចំណាយលើការធ្វើយុទ្ធនាការបង្ការ ការបោះបង់ការសិក្សានៅតាមសាលា និងសហគមន៍ និងសោហ៊ុយធ្វើដំណើរសម្រាប់មន្ត្រី ឬមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ កំណត់អត្តសញ្ញាណសិស្សដែលងាយ ឬប្រឈមនឹងការបោះបង់ចោលការសិក្សា។ | - 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ៣.៧.ចំណាយលើសោហ៊ុយធ្វើដំណើរសម្រាប់មន្ត្រី ឬមន្ត្រីការិយាល័យអប់រំយុវជន និងកីឡា ក្រុង ស្រុក សម្រាប់ចុះពិនិត្យ តាមដាន និងចុះសួរសុខទុក្ខតាមគ្រួសារ ដែលមានសិស្សប្រឈមនឹងការបោះបង់ការសិក្សា។ | |
| **៤.កិច្ចការពារស្ត្រី និងកុមារ ៖** សំដៅលើសកម្មភាពគាំទ្រលើកកម្ពស់ការយល់ដឹង និងយុទ្ធនាការស្តីពីការទប់ស្កាត់គ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន សុវត្ថិភាពកុមារពីការលង់ទឹក ការកេងប្រវ័ញ្ចសម្រាប់ជនរងគ្រោះជាស្ត្រីនិងកុមារ ដោយមានបើកវគ្គផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការកេងប្រវ័ញ្ច ការរំលោភបំពានលើកុមារ ការចិញ្ចឹមថែទាំកូនតាមបែបវិជ្ជមាន។ បណ្តុះបណ្តាល កម្លាំងសេវាសង្គម ភ្នាក់ងារសង្គមកិច្ច ជំនួយការសង្គម មន្ត្រីជំនាញពាក់ព័ន្ធក្នុងការអន្តរាគមន៍ជួយកុមារ ស្ត្រីរងគ្រោះ និងគ្រួសារ។ ការផ្តល់សេវាគ្រប់គ្រងនិងសមាហរណកម្ម ដល់កុមាររងគ្រោះតាមមណ្ឌលថែទាំជំនួសតាមសហគមន៍ និងមធ្យោបាយធ្វើដំណើរតាមការចាំបាច់របស់ជនរងគ្រោះដើម្បីទទួលសេវាផ្សេងៗ។ | |
| ៤.១.ចំណាយសោហ៊ុយធ្វើដំណើរ និងឧបត្ថម្ភសម្រាប់កុមារ ស្ត្រីរងគ្រោះ និងគ្រួសារក្រីក្រ រងគ្រោះ និងងាយរងគ្រោះ ដើម្បីទៅទទួលសេវា។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ៤.២.ចំណាយសោហ៊ុយដំណើរសម្រាប់មន្ត្រីសង្គមកិច្ច បុគ្គលិកសង្គមឬជំនួយការសេវាសង្គម និងមន្ត្រីអនុវត្តច្បាប់ក្នុងពេលអន្តរាគមន៍ជួយកុមារ ស្ត្រីរងគ្រោះ និងគ្រួសារ។ | - 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន" |

| | |
|---|---|
| ៤.៣.ចំណាយសោហ៊ុយដំណើរសម្រាប់គ្រូ និងសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល កម្លាំងសេវាសង្គម។ | - 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ៤.៤.ចំណាយសោហ៊ុយធ្វើដំណើរ សម្រាប់បុគ្គលិកសង្គមឬជំនួយការសេវាសង្គម ចុះបើកវគ្គដល់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ អ្នកសម្របសម្រួលកិច្ចការស្ត្រីនិងកុមារក្រុង ស្រុក ចុះបើកវគ្គបណ្តុះបណ្តាល មាតាបិតា និងអ្នកថែទាំកុមារស្តីពីការចិញ្ចឹមថែទាំកូនតាមបែបវិជ្ជមាន និងការគ្រប់គ្រងករណីកិច្ចការពារកុមារ។ | |
| ៤.៥.ចំណាយសម្រាប់វគ្គបណ្តុះបណ្តាលមន្ត្រីសង្គមកិច្ច និងអ្នកពាក់ព័ន្ធ ដើម្បីអភិវឌ្ឍសមត្ថភាព (ពាក់កណ្តាលអាជីព)។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ"<br>- 61093 "បុគ្គលិកសម្ភារសាធារណៈផ្សេងៗ" |
| ៤.៦.ចំណាយបើកវគ្គជំនាញវិជ្ជាជីវៈសម្រាប់គ្រួសារក្រីក្រ រងគ្រោះ និងងាយរងគ្រោះ ដើម្បីពង្រឹងសមត្ថភាព។ | |
| ៤.៧.ចំណាយសម្រាប់បើកវគ្គដល់មាតាបិតា អាណាព្យាបាល និងអ្នកថែទាំកុមារ ស្តីពីការចិញ្ចឹមថែទាំកូនតាមបែបវិជ្ជមាន ដើម្បីអភិវឌ្ឍសមត្ថភាពនិងផ្លាស់ប្តូរបទពិសោធន៍អ្នកចូលរួមពាក់ព័ន្ធ។ | |
| ៤.៨.ចំណាយលើជំនួយសង្គម (កញ្ចប់សមាហរណកម្មថវិកា អាហារ សម្ភារៈសិក្សា) ប្រាក់ឧបត្ថម្ភ (សោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅសម្រាប់កុមារ ស្ត្រី និងគ្រួសារ )សម្រាប់កុមារ ស្ត្រីរងគ្រោះ និងគ្រួសារក្នុងកំឡុងពេល ទទួលសេវា (រួមទាំងសេវាបកប្រែសម្រាប់ជនជាតិដើមភាគតិច) និងអំឡុងពេលបញ្ជូនត្រឡប់ទៅសហគមន៍តាមនីតិវិធីប្រព័ន្ធយុត្តិធម៌។ | |
| ៤.៩.ចំណាយបោះពុម្ពសៀវភៅកត់ត្រាព័ត៌មានភូមិ។ | - 60023 "ការបោះពុម្ព" |
| ៤.១០.ចំណាយសម្រាប់រៀបចំវគ្គតម្រង់ទិសស្តីពីអត្រានុកូលដ្ឋានគ្រប់ប្រភេទជាមួយ ស្មៀនឃុំ សង្កាត់ ជំនួយការឃុំ សង្កាត់ មន្ត្រីភូមិនិងអ្នកពាក់ព័ន្ធ ដើម្បីអភិវឌ្ឍសមត្ថភាពនិងផ្លាស់ប្តូរបទពិសោធន៍ ។ | - 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ៤.១១.ចំណាយសម្រាប់កិច្ចប្រជុំឆ្លុះបញ្ចាំងស្តីពីកិច្ចការពារស្ត្រីនិងកុមារ។ | |
| ៤.១២.ចំណាយលើមធ្យោបាយបំពេញការងាររបស់ភ្នាក់ងារសង្គមកិច្ចឃុំ សង្កាត់ និងក្រុង ស្រុក ក្នុងនោះមាន ទោចក្រយានយន្ត ត្រីចក្រយានយន្ត ឬរ៉ឺម៉ក កុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនថតចម្លង ម៉ាស៊ីនស្កេន និងការជួសជុលឧបករណ៍ និងប្រព័ន្ធបច្ចេកទេសព័ត៌មានវិទ្យា ជាដើម។ | - 60054 "សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន"<br>- 60055 "សម្ភារៈ និងបរិក្ខារបច្ចេកទេស ព័ត៌មានវិទ្យា" |

| | |
|---|---|
| | - 61057 "ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍ បច្ចេកទេស" |
| ៤.១៣.ចំណាយសោហ៊ុយធ្វើដំណើរចុះពិនិត្យតាមដាន គ្រប់ករណី និងការចុះធ្វើអធិការកិច្ចមណ្ឌលថែទាំរបស់អង្គការមិនមែនរដ្ឋាភិបាល។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ៤.១៤.ចំណាយរៀបចំកិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលរបស់ភ្នាក់ងារសង្គមកិច្ច ជំនួយការសង្គម និងអ្នកពាក់ព័ន្ធ ដើម្បីអភិវឌ្ឍសមត្ថភាព ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ៤.១៥. ចំណាយលើការអប់រំផ្សព្វផ្សាយអំពីការបង្ការ ការលង់ទឹក ជាពិសេសក្នុងចំណោមកុមារ និងមធ្យោបាយដឹកជញ្ជូនសិស្សមានសុវត្ថិភាពតាមផ្លូវទឹក។ | - 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ៤.១៦. ចំណាយសម្រាប់ការរៀបចំផែនទីសេវាសង្គម។ | - 60023 "ការបោះពុម្ព"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| **៥. ការលើកកម្ពស់សមភាពយេនឌ័រ ៖** សំដៅលើការគាំទ្រសកម្មភាពផ្សព្វផ្សាយអំពី ការផ្លាស់ប្តូរឥរិយាបទផ្នត់គំនិតអវិជ្ជមាន និងការអនុវត្តវិធានការសមស្របនានា ដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រី លើកកម្ពស់សមធម៌សង្គម និងបរិយាបន្ន...។ល។ | |
| ៥.១.ចំណាយរៀបចំវគ្គបណ្តុះបណ្តាល និងប្រជុំតម្រង់ទិស ការលើកកម្ពស់សមភាពយេនឌ័រដល់អ្នកអនុវត្ត និងអ្នកពាក់ព័ន្ធ។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល" |

| | |
|---|---|
| ៥.២.ចំណាយរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយ បណ្តុះបណ្តាល សិក្ខាសាលា ដល់អ្នកពាក់ព័ន្ធ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ៥.៣.ចំណាយលើការសិក្សាពីតម្រូវការយេនឌ័រ និងការតាមដានស្ថានភាពយេនឌ័រនៅតាមសហគមន៍ នៅក្នុងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ និងការរៀបចំ អនុវត្តផែនការសកម្មភាព។ | - 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| **៦.កិច្ចគាំទ្រ និងជំរុញការអនុវត្តកម្មវិធីគាំពារសង្គម ៖** សំដៅដល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីសកម្មភាពបង្កើនចំណូលគ្រួសារ និងផ្តល់សម្ភារៈប្រើប្រាស់ដើម្បីបម្រើសកម្មភាពគាំពារសង្គម។ ផ្តល់សេវាកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ (រាប់បញ្ចូលទាំងកុមារមានពិការ និងកុមារដែលមានឪពុកម្តាយធ្វើចំណាកស្រុក) និងស្ត្រីងាយរងគ្រោះដោយអំពើហិង្សា។ សេវាគាំទ្រជំនួយសង្គម និងសេវាផ្សេងៗសម្រាប់គ្រួសារក្រីក្រ កុមារក្រីក្រ កុមារដែលត្រូវឪពុកម្តាយធ្វើចំណាកស្រុក កុមាររស់នៅបែកបាក់គ្រួសារ ស្ត្រី ជនមានពិការភាព មនុស្សវ័យចាស់ គ្រួសារងាយរងគ្រោះ ការជួញដូរមនុស្ស និងគ្រឿងញៀន។ | |
| ៦.១.ចំណាយប្រាក់ឧបត្ថម្ភ សម្រាប់ជំនួយការសេវាសង្គម/ភ្នាក់ងារសង្គមកិច្ចរបស់ឃុំ សង្កាត់ ស្របតាមប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨។ | - 61093 "បុគ្គលិកសម្ងហភាពសាធារណៈផ្សេងៗ" |
| ៦.២.ចំណាយសោហ៊ុយធ្វើដំណើរ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ គ្រួសារងាយរងហានិភ័យ គ្រួសារងាយរងគ្រោះ និងជនងាយរងគ្រោះ ដូចជាកុមារ ជនមានពិការភាព ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ និងជនងាយរងគ្រោះផ្សេងទៀត ( កុមារក្រីក្រ រាប់បញ្ចូលទាំងកុមារពិការ និងកុមារដែលត្រូវបានទុកចោល ដោយសារឪពុកម្តាយធ្វើចំណាកស្រុក ព្រមទាំងកុមារនិងស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ។ | - 60015 "ប្រេងឥន្ទនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ៦.៣.ចំណាយសោហ៊ុយធ្វើដំណើរសម្រាប់បញ្ជូនកុមារ និងគ្រួសារងាយរងគ្រោះ ទៅរកសេវាជំនួយសង្គម។ | - 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ៦.៤.ចំណាយសោហ៊ុយធ្វើដំណើរសម្រាប់បុគ្គលិកសង្គមកិច្ច មន្ត្រីឃុំ សង្កាត់ និងបុគ្គលិកក្រៅក្របខណ្ឌ ផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងងាយរងគ្រោះ ចុះយុទ្ធនាការផ្សព្វផ្សាយ សម្ភាសន៍និងកំណត់ | - 60015 "ប្រេងឥន្ទនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន" |

| | |
|---|---|
| អត្តសញ្ញាណ អ្នកទទួលផល ពីកម្មវិធីគាំពារសង្គម កម្មវិធីអត្តសញ្ញាណកម្មជនមានពិការភាព កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងហានិភ័យ និងកម្មវិធីផ្សេងៗទៀតដែលជាមុខងារប្រតិភូកម្ម/ឬប្រគល់ដោយក្រសួងស្ថាប័ន និងមុខងារជាកាតព្វកិច្ច។ | - 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ៦.៥.បង្កលក្ខណៈ (ឧបត្ថម្ភជីវភាពគ្រួសារ) ការធ្វើសមាហរណកម្មកុមារ ពីមណ្ឌលថែទាំចូលទៅក្នុងសហគមន៍វិញ។ | - 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ៦.៦.ចំណាយឧបត្ថម្ភសម្រាប់៖<br>ក) គ្រួសារក្រីក្រ ដើម្បីការពារការបែកបាក់កូនពីគ្រួសារ ឬគ្រួសារក្រីក្រដែលធ្វើសមាហរណកម្មកូនត្រឡប់មកវិញ។<br>ខ) កុមារងាយរងគ្រោះ ក្រីក្រ ឪពុកម្តាយធ្វើចំណាកស្រុក។ | - 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ៦.៧. ចំណាយរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយ បណ្តុះបណ្តាល សិក្ខាសាលា ស្តីពីភូមិឃុំ សង្កាត់មានសុវត្ថិភាព។ | |
| ៦.៨ ចំណាយសម្រាប់កិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងគណៈកម្មាធិការសម្របសម្រួលកិច្ចការស្ត្រីនិងកុមារ សម្រាប់ការរៀបចំផែនការសកម្មភាពនិងថវិកាសេវាសង្គម និងតាមដានការអនុវត្តសកម្មភាពសេវាសង្គម ក្រុង ស្រុក និងឃុំ សង្កាត់ ។ | - 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស" |
| ៦.៩.ចំណាយដំណើរការកិច្ចប្រជុំ ផ្សព្វផ្សាយ បណ្តុះបណ្តាល សិក្ខាសាលា របស់ក្រុមការងារពហុវិស័យឆ្លើយតបអំពើហិង្សា ក្រុមការងារប្រឆាំងការជួញដូរគ្រឿងញៀន ក្រុមការងារប្រឆាំងការជួញដូរមនុស្ស។ និងផ្តល់សេវាជំនួយសង្គមដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងគ្រឿងញៀន។ | - 62028 "ជំនួយសង្គមផ្សេងៗទៀត"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស" |
| ៦.១០.ចំណាយឧបត្ថម្ភ (ផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ) ដល់មណ្ឌលបន្សាបគ្រឿងញៀន ដូចជា៖ គ្រែ កន្ទេល មុង ភួយ ជាដើម។ | - 62036 "ឧបត្ថម្ភដល់មណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍ" |

| | |
|---|---|
| ៦.១១. ចំណាយសេវាទូរស័ព្ទឬអ៊ីនធឺណេត សម្រាប់ថេបប្លេត ដំណើរការប្រព័ន្ធអេបនានា ពាក់ព័ន្ធនឹងកម្មវិធីគាំពារសង្គម កម្មវិធីអត្តសញ្ញាណកម្មជនមានពិការភាព កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងកម្មវិធីផ្សេងៗទៀតដែលជាមុខងារប្រតិភូកម្ម /ឬប្រគល់ដោយក្រសួងស្ថាប័ន និងមុខងារជាកាតព្វកិច្ច។ | - 61142 "សោហ៊ុយទូរគមនាគមន៍" |
| ៦.១២. ឧបត្ថម្ភជនចាស់ជរា សមាគមន៍ចាស់ជរា ជនមានពិការភាព និងជនងាយរងគ្រោះ។ | - 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ៦.១៣. បរិយាបន្នពិការភាពក្នុងកម្មវិធីជាតិជំនួយសង្គម និងសេវាសង្គម ចំណាយរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយ បណ្តុះបណ្តាល សិក្ខាសាលា កម្មវិធីឬសកម្មភាពកំសាន្ត ពាក់ព័ន្ធនឹងការងារ លើកកម្ពស់បរិយាបន្នពិការភាព ក្នុងកម្មវិធីជាតិជំនួយសង្គម កញ្ចប់សេវាសង្គមសម្រាប់ជនមានពិការភាព ការបង្ការការរើសអើង នៅក្នុងសហគមន៍ ផ្តល់ការគាំទ្រ ឬជំនួយសង្គ្រោះបឋម បង្កើនការយល់ដឹងពីសិទ្ធិជនមានពិការភាព ជំរុញ និងសម្របសម្រួលជនមានពិការចុះឈ្មោះចូលក្នុងកម្មវិធីជាតិជំនួយសង្គម និងសេវាសង្គមនានា។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ"<br>- 60053 "សម្ភារៈប្រើប្រាស់"<br>- 60052 "សង្ហារិម"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទនិងសំណង់ផ្សេងៗ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ"<br>- 21031 "សំណង់អគារ"<br>- 21032 "កែលម្អអគារ"<br>- 21048 "ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ" |
| ៦.១៤. ការងារអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋានដែលរួមមាន ការផ្សព្វផ្សាយ ការចុះសម្ភាសន៍ ការប្រមូលទិន្នន័យ កំណត់អត្តសញ្ញាណ ត្រួតពិនិត្យ និងផ្តល់បណ្ណសម្គាល់ជនមានពិការភាព។ | |
| ៦.១៥. រៀបចំផាសុកវត្ថុ និងផាសុកសមរម្យសម្រាប់ជនមានពិការភាព (Accessibility) នៅតាមសាលាក្រុង ស្រុក ឃុំ សង្កាត់ សាលារៀនមណ្ឌលសុខភាព មន្ទីរពេទ្យ និងទីសាធារណៈផ្សេងៗទៀត (ឧទាហរណ៍ ជំរេលបន្ទប់ទឹក) បង្កើនការយល់ដឹងអំពីឧបករណ៍ជំនួយសម្រាប់ជនមានពិការភាព និងសេវាស្តារលទ្ធភាពពលកម្ម ដើម្បីជួយសម្របសម្រួលជនមានពិការភាពទៅរកសេវា កំណត់ស្ថានភាព និងតម្រូវការផ្នែកផាសុកវត្ថុ និងផាសុកសមរម្យ (Accessibility) របស់ជនមានពិការភាព នៅឃុំ សង្កាត់ និងក្រុង ស្រុក។ | |

| | |
|---|---|
| **៧. ពង្រឹងការយល់ដឹង និងទប់ស្កាត់ ការរីករាលដាលជំងឺឆ្លង និងជំងឺមិនឆ្លង ៖** សំដៅដល់ការផ្តល់សេវាទាក់ទងនឹងជំងឺឆ្លង និងជំងឺមិនឆ្លង គឺជាផ្នែកមួយនៃសេវាសង្គម ដែលត្រូវពិចារណាគ្រោងនិងអនុវត្ត ដោយកំណត់សកម្មភាពជាក់លាក់សមស្របនឹងស្ថានភាព កម្រិតថវិកា របស់រដ្ឋបាលនីមួយៗ និងការផ្សព្វផ្សាយអំពីជំងឺរាតត្បាតផ្សេងៗ។ សកម្មភាពសំខាន់ៗដូចជា៖ ការកំណត់អត្តសញ្ញាណអ្នកកើតមេរោគអេដស៍ ការវិភាគបញ្ហា តម្រូវការ និងដំណោះស្រាយ ចំពោះបញ្ហាជំងឺឆ្លង និងមិនឆ្លងក្នុងសហគមន៍ និងដំណើរការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវា និងអន្តរាគមន៍ជាក់ស្តែងទាក់ទងនឹងបញ្ហាខាងលើ។ | |
| ៧.១.ចំណាយរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយ បណ្តុះបណ្តាល សិក្ខាសាលា ដល់អ្នកពាក់ព័ន្ធ ដើម្បីអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ៧.២.ចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ បង្កើនការយល់ដឹងតាមសហគមន៍ (តាមភូមិ ឬមណ្ឌលសុខភាព ឬនៅសាលាឃុំ សង្កាត់ ឬនៅតាមសាលារៀន) អំពីការបង្ការនិងទប់ស្កាត់ ការរីករាលដាលជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈផ្សេងៗ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន" |
| ៧.៣.ចំណាយសម្រាប់ការធ្វើដំណើររបស់បុគ្គលិកមណ្ឌលសុខភាព ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យ និងមន្ត្រី ឬបុគ្គលិកក្រៅក្របខណ្ឌ ដើម្បីផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីការបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈផ្សេងៗនៅតាមសហគមន៍។ | |
| ៧.៤.ចំណាយប្រាក់ឧបត្ថម្ភសម្រាប់អ្នកទ្រទ្រង់សុខភាពភូមិ អនុវត្តយុទ្ធនាការផ្សព្វផ្សាយ បង្កើនការយល់ដឹងតាមសហគមន៍ (តាមភូមិ ឬមណ្ឌលសុខភាព ឬនៅសាលាឃុំ សង្កាត់ ឬនៅតាមសាលារៀន) អំពីការបង្ការនិងទប់ស្កាត់ ការរីករាលដាលជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈផ្សេងៗ។ | - 61093 "បុគ្គលិកសម្ងហភាពសាធារណៈផ្សេង"<br>- 61091 "ចំណាយលើការជួលទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិខ្មែរ និងបុគ្គលិកជាប់កិច្ចសន្យាដែលជ្រើសរើសដោយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផ្ទាល់"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន" |

| | |
|---|---|
| **៨. ការលើកកម្ពស់គណនេយ្យភាពសង្គម ៖** សំដៅលើសកម្មភាពផ្សព្វផ្សាយព័ត៌មាន សេវាកម្ម និងលើកកម្ពស់តម្លាភាព ជូនប្រជាពលរដ្ឋ និងសាធារណៈ (តាមរយៈការប្រជុំ សិក្ខាសាលា បិទផ្សាយជាសាធារណៈ ស្ដីពីទម្រង់ថវិកាសង្ខេបរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ កញ្ចប់ព័ត៌មានរបស់ប្រជាពលរដ្ឋ I4Cs លទ្ធផលបំពេញការងារ ការរៀបចំ និងការប្រើប្រាស់ថវិកា និងចែកចាយផ្ទាំងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ អង្គភាពផ្តល់សេវាពាក់ព័ន្ធ...ល)។ បង្ហាញ និងពិភាក្សាអំពីលទ្ធផល I4Cs ក្នុងកិច្ចប្រជុំថ្នាក់ក្រុង ស្រុកនិងឃុំ សង្កាត់។ កសាងសមត្ថភាពដល់អ្នកសម្របសម្រួល និងផ្តល់សេវាគណនេយ្យភាពសង្គមតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិស ក្នុងការបង្កើនការយល់ដឹង និងការអភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវា ក្នុងការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និងអ្នកបច្ចេកទេស។ | |
| ៨.១.រៀបចំវគ្គបណ្តុះបណ្តាលនិងប្រជុំតម្រង់ទិស ដល់អ្នកផ្តល់សេវាគណនេយ្យភាពសង្គម ដើម្បីអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស "<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត"<br>- 60021 "សម្ភារៈការិយាល័យ"<br>- 60023 "ការបោះពុម្ព"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61093 "បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ" |
| ៨.២.រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារ ផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស) ។ | |
| ៨.៣.ចំណាយរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយ បណ្តុះបណ្តាល ដល់ភាគីពាក់ព័ន្ធ។ | |
| ៨.៤. ចំណាយលើការបោះពុម្ព បិទផ្សព្វផ្សាយ និងប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងក្រុមយុវជនលើទម្រង់ថវិកាសង្ខេប របស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ (អនុវត្តសេចក្តីណែនាំ០២៥ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំ និងអនុម័តថវិកាឃុំ សង្កាត់ និងសេចក្តីណែនាំពាក់ព័ន្ធសម្រាប់រដ្ឋបាលក្រុង ស្រុក)។ | |
| ៨.៥. រៀបចំក្តារព័ត៌មាន និងបោះពុម្ព I4Cs សម្រាប់ផ្សព្វផ្សាយជូនប្រជាពលរដ្ឋ។ | |
| ៨.៦. ជួលមធ្យោបាយដឹកជញ្ជូនចល័ត (ម៉ូតូកង់បី ឬឡាន) ដើម្បីចាក់ឧបករណ៍បំពងសម្លេង តាមភូមិ និងសហគមន៍ អំពីព័ត៌មានសិទ្ធិស្តង់ដាការបំពេញការងារ និងថវិការបស់អង្គភាពផ្តល់សេវា។ | |
| ៨.៧. ឧបត្ថម្ភគាំទ្រដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដើម្បីធានានូវនិរន្តរភាព នៃការអនុវត្តការងារគណនេយ្យភាពសង្គម។ | |

| | |
|---|---|
| **II. សេវាអនាម័យបរិស្ថាន** | |
| **៩.ទឹកស្អាត និងអនាម័យ ៖** សំដៅដល់ការលើកកម្ពស់ទឹកស្អាត អនាម័យ និងការពង្រឹងសមត្ថភាពមន្ត្រីរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ទាក់ទងនឹងការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានភាពធន់នឹងអាកាសធាតុ។ គាំទ្រការវិភាគផលប៉ះពាល់ហានិភ័យអាកាសធាតុលើបរិក្ខារ និងការផ្តល់សេវាកម្មទឹកស្អាតនិងអនាម័យ នៅថ្នាក់ក្រោមជាតិ និងការបង្កើតសកម្មភាពឆ្លើយតបនឹងហានិភ័យ ដែលមានភាពធន់នឹងអាកាសធាតុ។ ពង្រឹងការប្រមូលទិន្នន័យទាក់ទងនឹងកម្រិតគ្របដណ្តប់នៃបរិក្ខារទឹកស្អាត និងអនាម័យដែលមានភាពធន់នឹងអាកាសធាតុ នៅតាមសាលារៀន មណ្ឌលសុខភាព និងតាមសហគមន៍។ ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពីការលើកកម្ពស់ទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុតាមសាលារៀន និងតាមសហគមន៍។ | |
| ៩.១.ចំណាយសម្រាប់ជួសជុល សាងសង់ និងកែលម្អបរិក្ខារកន្លែងលាងដៃ បង្គន់ នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាលដែលមានភាពធន់នឹងអាកាសធាតុ និងគិតគូរពីផាសុកវត្ថុ និងផាសុកសមរម្យសម្រាប់ជនមានពិការភាព (Accessibility)។ | - 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ"<br>- 21048 "ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ" |
| ៩.២.ចំណាយសាងសង់ ជួសជុល និងកែលម្អអណ្តូងទឹក ការតភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹក នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល មានភាពធន់នឹងអាកាសធាតុ និងគិតគូរពីផាសុកវត្ថុ និងផាសុកសមរម្យ សម្រាប់ជនមានពិការភាព (Accessibility)។ | - 61054 "ការថែទាំបណ្តាញផ្សេងៗ"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ"<br>- 21048 "ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ" |
| ៩.៣.បំពាក់ម៉ាស៊ីន ឬប្រព័ន្ធចម្រោះទឹកស្អាតនៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាលដោយគិតគូរពីផាសុកវត្ថុ និងផាសុកសមរម្យ សម្រាប់ជនមានពិការភាព (Accessibility)។ | - 60051 "សម្ភារៈ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា" |
| ៩.៤.ការផ្តល់សាប៊ូនិងសម្ភារៈសម្អាតអនាម័យនៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។ | - 60011 "សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ" |
| ៩.៥.ការផ្តល់ធុងទឹក ឬធុងចម្រោះទឹកស្អាត នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។ | - 60053 "សម្ភារៈប្រើប្រាស់" |

| | |
|---|---|
| ៩.៦.ទិញបង្គន់ចល័តសម្រាប់ប្រើប្រាស់នៅតាមសាលារៀន (រួមទាំងមត្តេយ្យសិក្សា) នៅតាមមូលដ្ឋានសុខាភិបាល និងតាមទីសាធារណៈ ដោយគិតគូរពីផាសុកវត្ត និងផាសុកសមរម្យសម្រាប់ជនមានពិការភាព (Accessibility)។ | - 60058 "ការទិញសម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខាផ្សេងៗ" |
| ៩.៧.ចំណាយមធ្យោបាយធ្វើដំណើររបស់បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡា និងការិយាល័យពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចប្រជុំបង្កើនការយល់ដឹង គាំទ្រដល់ការវិភាគផលប៉ះពាល់ហានិភ័យអាកាសធាតុលើបរិក្ខារនិងការផ្តល់សេវាកម្មទឹកស្អាតនិងអនាម័យ និងរៀបចំបង្កើតសកម្មភាពឆ្លើយតប និងអនុវត្តផែនការលើកកម្ពស់ទឹកស្អាត និងអនាម័យ ដែលមានភាពធន់នឹងអាកាសធាតុតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| ៩.៨.ចំណាយមធ្យោបាយធ្វើដំណើរ រៀបចំកិច្ចប្រជុំបំផុស និងអនុវត្តផែនការសម្រាប់សហគមន៍ ដឹកនាំអនាម័យ ទាំងស្រុងនៅតាមសហគមន៍នានា។ | |
| ៩.៩.ចំណាយឧបត្ថម្ភដល់សហគមន៍ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការផ្តល់សេវាអនាម័យដែលមានភាពធន់នឹងអាកាសធាតុដូចជា៖ ការសាងសង់ ជួសជុល និងកែលម្អអណ្តូងទឹក/បង្គន់ ឱ្យមានភាពធន់នឹងអាកាសធាតុ និងការតភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹក ការទិញបង្គន់ចល័តនៅតាមសហគមន៍ជាដើម ដោយគិតគូរពីផាសុកវត្ត និងផាសុកសមរម្យ សម្រាប់ជនមានពិការភាព (Accessibility)។ | - 21031 "សំណង់អគារ"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ"<br>- 61058 "ការថែទាំ និងជួសជុលផ្សេងៗ"<br>- 62031 "ឧបត្ថម្ភសហគមន៍និងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសង្គម" |
| ៩.១០.ចំណាយសម្រាប់រៀបចំវគ្គបំផុសសហគមន៍ ដឹកនាំអនាម័យទាំងស្រុង នៅតាមសហគមន៍លើសកម្មភាព នៃការផ្តល់ចំណេះដឹង ដើម្បីអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ៩.១១.ចំណាយសម្រាប់បុគ្គលិក ទទួលបន្ទុកកិច្ចការទឹកស្អាតនិងអនាម័យ រៀបចំកិច្ចប្រជុំបង្កើនការយល់ដឹង គាំទ្រដល់ការវិភាគផលប៉ះពាល់ហានិភ័យអាកាសធាតុ លើបរិក្ខារនិងការផ្តល់សេវាកម្ម ទឹកស្អាតនិងអនាម័យ | |

| | |
|---|---|
| និងរៀបចំបង្កើតសកម្មភាពឆ្លើយតប និងអនុវត្តផែនការលើកកម្ពស់ទឹកស្អាត និងអនាម័យដែលមានភាពធននឹងអាកាសធាតុ តាមសាលារៀន រួមទាំងសាលាមត្តេយ្យ និងនៅតាមមូលដ្ឋានសុខាភិបាល។ | |
| ៩.១២. ចំណាយប្រាក់ឧបត្ថម្ភសម្រាប់អ្នកប្រមូលទិន្នន័យក្រុង ស្រុក ឃុំ សង្កាត់ ពាក់ព័ន្ធទឹកស្អាតនិងអនាម័យ។ | - 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" |
| **១០. ការគ្រប់គ្រងសំណល់រឹង រាវ ៖** សំដៅដល់សកម្មភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹង រាវ តាមទីប្រជុំជន និងមូលដ្ឋានរបស់រដ្ឋបាលសាមី ដែលមានដូចជាការប្រជុំកំណត់សកម្មភាព និងបញ្ហានានា ការអប់រំបណ្តុះបណ្តាល ការទិញសម្ភារៈអនាម័យ ដែលមានដូចជាធុងសំរាម ការថែទាំបរិស្ថាន ការជួសជុលថែទាំ និងកសាងលូបង្ហូរទឹក សម្រាប់រដ្ឋបាលនីមួយៗ។ | |
| ១០.១.ទិញសម្ភារៈសំអាតនិងអនាម័យ ដូចជា ធុងសំរាម, ធុងទឹក និងសម្ភារៈអនាម័យផ្សេងៗ បំពាក់តាមទីសាធារណៈ, សាលារៀន, មណ្ឌលសុខភាព, សួនសាធារណៈ...។ល។ | - 60011 "សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ"<br>- 61011 "សេវាអនាម័យ"<br>- 61038 "ថ្លៃឈ្នួល និងបន្ទុក(អសង្ហារិម) ផ្សេងៗ"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ១០.២. ចំណាយលើសម្ភារៈសម្រាប់អប់រំបណ្តុះបណ្តាល ទាក់ទងការធ្វើឱ្យប្រសើរឡើង ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង រាវ (ឧ. ធុងសំរាម ប៉ែល ការរចនាទីតាំងសម្រាប់ធ្វើជីកំប៉ុសតាមផ្ទះ ម៉ាស៊ីនគ្រីបសំរាប់វេចខ្ចប់សំរាម...។ល។) | |
| ១០.៣.ចំណាយលើការបង់សេវាទីលានទុកដាក់សំរាម រៀបចំទីលានផ្ទុកសំរាមកែច្នៃនិង ការជួលក្រុមហ៊ុនសហគ្រាស ដែលផ្តល់សេវាសំអាត ប្រមូល និងដឹកជញ្ជូនសំណល់រឹង រាវ។ | |
| ១០.៤.ចំណាយលើការរៀបចំកន្លែងទុកដាក់សំរាម ឬធុងសំរាមលើទឹក ឬកន្លែងសមស្របសំរាប់ស្តុកសំរាមដើម្បីដឹកជញ្ជូនបន្តទៅទីលានទុកដាក់សំរាម។ | |
| ១០.៥. ចំណាយលើការទិញសម្ភារៈដឹកសំរាម (តុកតុក ទូក ឬម៉ែក) ពីទីតាំងបង្កើតសំរាមទៅទីតាំងនានា (ទីតាំងស្តុកសំរាម ទីលានទុកដាក់សំរាម ស្ថានីយ៍ជីកំប៉ុស ស្ថានីយកែច្នៃ) | - 60011 "សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន" |
| ១០.៦. ចំណាយលើយុទ្ធនាការផ្សព្វផ្សាយសំអាតសំរាមផ្លាស្ទិកសំណល់រឹង រាវ នៅតាមទីសាធារណៈ, សាលារៀន,មណ្ឌលសុខភាពមូលដ្ឋាន និងសហគមន៍។ | |

| | |
|---|---|
| ១០.៧. ចំណាយលើយុទ្ធនាការផ្សព្វផ្សាយ ការពិន័យអន្តរការណ៍ និងចុះត្រួតពិនិត្យធ្វើការពិន័យចំពោះ អំពើល្មើសបោះចោលសំរាម សំណល់រឹងនៅទីប្រជុំជននៅទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬ កន្លែងហាមឃាត់ការបោះចោលសំរាមសំណល់រឹង។<br>១០.៨. ចំណាយលើការចុះត្រួតពិនិត្យ រៀបចំ និងសំអាតទីតាំងសំណល់រាវ តាមទីសាធារណៈ។ | - 62028 "ជំនួយសង្គមផ្សេងៗទៀត"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61128 "សោហ៊ុយក្នុងប្រទេសផ្សេងៗ" |
| ១០.៩. ចំណាយសាងសង់ចង្រ្កាន ឬឡដុតសំរាមមិនមែនជាផលិតផលប្លាស្ទិក ដែលមិនអាចកែច្នៃឡើងវិញបាន។ | - 21038 "សំណង់ផ្សេងៗ" |
| ១០.១០. ចំណាយសម្រាប់បង់ថ្លៃសេវាប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងសំរាម។ | - 61073 "សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ |
| ១០.១១. ចំណាយលើការគាំទ្រដំណើរការកិច្ចប្រជុំនានា ទាក់ទងនឹងការធ្វើឱ្យប្រសើរឡើង ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង រាវ។ | - 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" |
| ១០.១២. ចំណាយលើការឃោសនា និងរៀបចំផ្ទាំងផ្សព្វផ្សាយព័ត៌មានបរិស្ថាន រៀបចំផ្ទាំងប៉ាណូ ស្លាកសញ្ញាចល័ត ពីការពង្រឹងនិងលើកកម្ពស់បរិស្ថាន មានដូចជាៈការអប់រំសំអាតបរិស្ថាន ការចោល និងញែកសំរាម ការពិន័យបទល្មើសចោលសំរាម។ល។ | - 61107 "ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ" |
| ១០.១៣. ចំណាយលើការជួលកម្មករ អ្នកបោសសំអាត អ្នកប្រមូលសំរាមតាមទីសាធារណៈ សួនច្បារ និងទីកន្លែងរៀបចំកម្មវិធីតាមទីសាធារណៈនានាដូចជាការតាំងពិព័រណ៌, ការប្រគុំតន្ត្រី...។ល។ | - 61098 "បុគ្គលិកខាងក្រៅផ្សេងៗ" |
| **១១. ការប្រែប្រួលអាកាសធាតុ ៖** សំដៅដល់សកម្មភាពក្នុងការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាលតាមទីប្រជុំជន និងមូលដ្ឋានរបស់រដ្ឋបាលសាមី អំពីសកម្មភាពទប់ស្កាត់ពីកម្មវិបាកនៃការប្រែប្រួលអាកាសធាតុ សម្រាប់រដ្ឋបាលនីមួយៗ។ | |
| ១១.១.ចំណាយលើការបង្កើត និងអនុវត្តផែនការសកម្មភាពថ្នាក់ក្រោមជាតិដើម្បីឆ្លើយតប នឹងហានិភ័យអាកាសធាតុ កុមារកំពុងជួបប្រទះ ដោយផ្អែកលើទិន្នន័យសន្ទស្សន៍ហានិភ័យអាកាសធាតុ លើកុមារសម្រាប់ប្រទេសកម្ពុជា។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |

| | |
|---|---|
| ១១.២.រៀបចំវគ្គបណ្តុះបណ្តាលនិងប្រជុំតម្រង់ទិសដល់អ្នកអនុវត្ត និងភាគីពាក់ព័ន្ធ ដើម្បីអភិវឌ្ឍសមត្ថភាព។<br>១១.៣.រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារ។<br>១១.៤.ចំណាយរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយ សិក្ខាសាលា បណ្តុះបណ្តាល ដល់ភាគីពាក់ព័ន្ធទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងហានិភ័យអាកាសធាតុដែលកុមារកំពុងជួបប្រទះដោយផ្អែកលើទិន្នន័យសន្ទស្សន៍ ហានិភ័យអាកាសធាតុលើកុមារសម្រាប់ប្រទេសកម្ពុជា។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ១១.៥. ចំណាយជួយជនរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ។ ជន្លៀសប្រជាជនទៅរកទីទួលសុវត្ថិភាព និងផ្តល់ជម្រកបណ្តោះអាសន្ន។ | - 60015 "ប្រេងឥន្ទនៈ និងប្រេងរំអិល"<br>- 60053 "សម្ភារៈប្រើប្រាស់"<br>- 60058 "សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 62023 "អាហារ និងសម្ភារៈ(ស្បៀង)"<br>- 62024 "ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |
| ១១.៦. ចំណាយលើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដូចជាដំឡើងសូឡាតាមសាលារៀន និងមណ្ឌលសុខភាព។ | - 60051 "សម្ភារៈ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា" |
| ១១.៧. ចំណាយដាំដើមឈើឡើងវិញ ការពារព្រៃឈើដែលមានស្រាប់ គាំទ្រដល់ការប្រើគ្រាប់ពូជ ដំណាំដែលធន់នឹងអាកាសធាតុរាំងស្ងួត ឬទឹកជំនន់ និងគាំទ្រសកម្មភាពល្បាតព្រៃ បឹងសហគមន៍។ | - 60015 "ប្រេងឥន្ទនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61051 "ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 62028 "ជំនួយសង្គមផ្សេងៗទៀត" |

<table>
<tr><td>១១.៨. ចំណាយជួសជុល ស្តារ និងសាងសង់ ប្រព័ន្ធធារាសាស្ត្រ រក្សាទឹកទប់ទល់នឹងភាពរាំងស្ងួត ទឹកជំនន់ និងអាងស្តុកទឹក។</td><td rowspan="2">- 21041 "ផ្លូវថ្នល់ ផ្លូវទឹក"<br>- 21042 "ធារាសាស្ត្រ"<br>- 61053 "ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន លូ"<br>- 61054"ការថែទាំបណ្តាញផ្សេងៗ"<br>- 61055"ការថែទាំប្រព័ន្ធធារាសាស្ត្រ"</td></tr>
<tr><td>១១.៩. ចំណាយជួសជុល និងសាងសង់ ហេដ្ឋារចនាសម្ព័ន្ធនានា ដើម្បីបញ្ចៀសទឹកជំនន់ក្នុងសហគមន៍ ប្រព័ន្ធស្តុកទឹកភ្លៀង ទឹកខូចគុណភាព។</td></tr>
</table>